**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No [illegible] MOC / M 2004

ភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ ៥១៤ សហវ-ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនប័ត្រផ្សេងៗ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងតាមការចាំបាច់ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួង

## <u>សំរេច</u>

**ប្រការ ១ :** រាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានបង្កើតឡើងនិងធ្វើពាណិជ្ជកិច្ច ហើយមិនទាន់បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវមានកាតព្វកិច្ចមកចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២ :** ដើម្បីធានាអះអាង និង ទទួលខុសត្រូវលើរាល់សំណុំលិខិតដែលខ្លួនបានបំពេញ ឬ ដែលខ្លួនត្រូវបំពេញ និង ផ្តល់មកតំកល់ទុកនៅនាយកដ្ឋាននីតិកម្មក្រសួងពាណិជ្ជកម្ម អភិបាលម្នាក់ ឬ ម្ចាស់ហ៊ុនម្នាក់ ត្រូវមកចុះហត្ថលេខាដោយផ្ទាល់ដៃ នៅចំពោះមុខមន្ត្រីនាយកដ្ឋាននីតិកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard. Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

បញ្ជាក់ថា រាល់សំណុំ លិខិតទាំងឡាយនេះ ពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ព្រមទាំងបង់សោហ៊ុយចំណាយដោយផ្ទាល់ដៃនៅលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣** : សោហ៊ុយចំណាយលើបែបបទ សុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម :

| | |
|---|---|
| -អាករលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | : 70 USD ( ចិតសិបដុល្លារអាមេរិក ) |
| -ទម្រង់បែបបទសុំចុះបញ្ជីពាណិជ្ជកម្ម | : 30 USD ( សាមសិបដុល្លារអាមេរិក ) |
| -ឆែកឈ្មោះ | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -ផ្តល់អត្តលេខចុះបញ្ជី | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -សភាពាណិជ្ជកម្ម | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |
| -ព្រឹត្តិប័ត្រពាណិជ្ជកម្ម | : 10 USD ( ដប់ដុល្លារអាមេរិក ) |
| -ធ្វើត្រា | : 12 USD ( ដប់ពីរដុល្លារអាមេរិក ) |
| -រាជកិច្ច | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -មន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |

បូកសរុបសោហ៊ុយចំណាយលើបែបបទចុះបញ្ជី: 177 USD ( មួយរយចិតសិបប្រាំពីរដុល្លារអាមេរិក )

**ប្រការ ៤** : នាយកដ្ឋាននីតិកម្ម មានកាតព្វកិច្ចផ្តល់គំរូលក្ខន្តិកៈក្រុមហ៊ុនឱ្យអ្នកចុះបញ្ជី ។ ក្នុងករណីអ្នកចុះបញ្ជី ពឹងពាក់មេធាវី ឬក្រុមហ៊ុនច្បាប់ណាមួយជួយបំពេញ លក្ខន្តិកៈឱ្យខ្លួន សោហ៊ុយសេវានេះគឺស្ថិតនៅក្រៅវង្វង់អំណាចរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ។ ក្រសួងពាណិជ្ជកម្មមិនទទួលខុសត្រូវលើសេវានោះទេ ។

**ប្រការ ៥** : នាយកដ្ឋាននីតិកម្ម ត្រូវមានវិធានការសមស្រប ដើម្បីសហការជាមួយអភិបាល ឬ ម្ចាស់ហ៊ុនដែលមកសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដើម្បីជួយណែនាំ និង បង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីពាណិជ្ជកម្មអោយបានឆាប់រហ័ស និង ទាន់ពេលវេលា ។

**ប្រការ ៦** : អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋាននីតិកម្ម និង មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់តាមខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ ៧** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

ចំលងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
-ទីស្តីការគណៈរដ្ឋមន្ត្រី ( ជូនជ្រាបជារបាយការណ៍ )
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
-ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ( ដើម្បីជួយផ្សព្វផ្សាយ )
-អភិបាលខេត្ត-ក្រុង ( ដើម្បីជួយផ្សព្វផ្សាយ )
-ឯកសារ-កាលប្បវត្តិ
-រាជកិច្ច ⁄

Prakas on commercial rigistration inspection/LAD/Sokun/SH

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones